**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច ការងារ**

**និង អតីតយុទ្ធជន**

លេខ: ២៩៧ សកអ

*រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ១៩៩៨*

# ប្រកាស

# ស្តីពី

# ការបើកវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈដល់ក្មេងសំរាប់ធ្វើការក្រោមដី

## រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញមាត្រា ១៧៤ នៃច្បាប់ស្តីពីការងារ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស-រកម-០៣៩៧-០១ ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ១៩៩៧

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត.១០៩៤-៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត.១០៩៤-៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរដ្ឋាភិបាល

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

- បានឃើញព្រះរាជក្រម លេខ នស-រកម-០១៩៦-១៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន

- បានឃើញអនុក្រឹត្យ លេខ ៥៦ អនក្រ-បក ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការ

ប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ។

## សំរេច

### ប្រការ ១

ក្មេងអាយុពី១៦ឆ្នាំ ទៅក្រោម១៨ឆ្នាំ អាចប្រើឱ្យធ្វើការនៅអណ្តូងរ៉ែ ឬការយក កំរៃ ឬ យកថ្មក្រោមដី បានតែក្នុងគោលបំណងហ្វឹកហ្វឺនវិជ្ជាជីវៈ និងជួយក្មេងមានទម្លាប់ទៅនឹងមុខរបរនាពេលអនាគតរបស់ខ្លួនប៉ុណ្ណោះ ។ ការប្រើក្មេងក្នុងមុខរបរប្រភេទនេះ ត្រូវស្ថិតក្រោមលក្ខខណ្ឌយ៉ាងតឹងរឹងដូចខាងក្រោម ។

### ប្រការ ២

មុននឹងចូលធ្វើការក្មេងត្រូវទទួលការពិនិត្យកាយសម្បទាយ៉ាងម៉ត់ចត់ពីគ្រូពេទ្យការងាររួមបញ្ចូលទាំងការថតសួតដោយវិទ្យុផង។ ចំណាយលើការត្រួតពិនិត្យកាយសម្បទា គឺជាបន្ទុករបស់ និយោជក។ វិញ្ញាបនប័ត្រកាយសម្បទាដែលចេញដោយគ្រូពេទ្យការងារត្រូវរក្សាទុកដោយនិយោជក និងត្រូវបង្ហាញជូនអធិការការងារ ឬអធិការពេទ្យការងារតាមសំណើ។ ការពិនិត្យកាយសម្បទានេះត្រូវធ្វើឡើងវិញរៀងរាល់រយៈពេល ៦ ខែ ។

### ប្រការ ៣

និយោជកត្រូវមានសៀវភៅបញ្ជីសំរាប់ក្មេងដោយឡែកដែលក្នុងនោះត្រូវបញ្ជាក់ច្បាស់អំពី :

- អាយុក្មេង
- កាលបរិច្ឆេទនៃការចុះក្រោមដី លើកទីមួយ
- ថិរវេលាសំរាកប្រចាំសប្តាហ៍
- ថិរវេលាសំរាកប្រចាំឆ្នាំ ។

### ប្រការ ៤

មុននឹងចុះទៅធ្វើការក្រោមដី ក្មេងត្រូវទទួលការបណ្តុះបណ្តាលពិសេសដោយគ្រូស្ទាត់ជំនាញ អំពី :

- គ្រោះថ្នាក់ដែលអាចកើតមាន ចំពោះសុខភាព និងសន្តិសុខការងារនៅក្រោមដី
- ការសង្គ្រោះបន្ទាន់
- វិធានការការពារគ្រោះថ្នាក់ ការប្រើប្រាស់បរិក្ខាសុវត្ថិភាព និងសេចក្តី ណែនាំអំពីសន្តិសុខ ។

### ប្រការ ៥

ក្មេងដែលធ្វើការក្រោមដី ត្រូវតែស្ថិតក្រោមការដឹកនាំរបស់គ្រូបង្ហាត់ដែលមានការទទួលខុសត្រូវខ្ពស់ ។ ក្នុងករណីនេះ ក្មេងអាចជួយការងារក្នុងក្រុមដើម្បីមានទម្លាប់ទៅនឹងមុខរបរអនាគតរបស់ខ្លួន ប៉ុន្តែពេលវេលាហ្វឹកហ្វឺនពិតប្រាកដយ៉ាងហោចណាស់ក៏ត្រូវស្មើនឹងពាក់កណ្តាល នៃពេលវេលាធ្វើការទាំងអស់របស់ក្មេងនៅ

ក្រោមដីដែរ ។

**ប្រការ ៦**

ក្មេងដែលធ្វើការក្រោមដី មិនត្រូវទុកឱ្យធ្វើការដោយគ្មានការឃ្លាំមើលឡើយ ។ ហាមឃាត់មិនឱ្យប្រើក្មេងកាន់ឧបករណ៍គ្រឿងយន្តណា ឬប្រើប្រាស់នូវរបៀបធ្វើអាជីវកម្មណាដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់ក្មេង ។

**ប្រការ ៧**

ក្មេងមិនអាចធ្វើការនៅក្រោមដីលើសពី៤០ម៉ោងក្នុងមួយសប្តាហ៍ ឬ ៨ ម៉ោង ក្នុងមួយថ្ងៃឡើយ ។

**ប្រការ ៨**

ក្មេងដែលធ្វើការក្រោមដីត្រូវបានឈប់សំរាកប្រចាំសប្តាហ៍ ដែលមានថិរវេលាយ៉ាងហោចណាស់ ៤៨ ម៉ោង ជាប់គិតរួមបញ្ចូលទាំងថ្ងៃអាទិត្យ និងមានសិទ្ធិឈប់សំរាកប្រចាំឆ្នាំចំនួន ២៤ ថ្ងៃបើបានធ្វើការជាប់ក្នុងមួយឆ្នាំទោះបីជាការធ្វើការនៅក្រោមដីមានលក្ខណៈមិនពេញពេលក៏ដោយ ។

**ប្រការ ៩**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ចម្លងជូន :**

- ព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២
- គ្រប់ក្រសួង "ដើម្បីជ្រាប"
- ក្រសួងពតិមាន "ដើម្បីផ្សព្វផ្សាយឱ្យបានទូលំទូលាយ"
- គ្រប់បណ្តាវិទ្យុ និងទូរទស្សន៍
- រាជកិច្ច
- គ្រប់អធិការដ្ឋានសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ខេត្ត-ក្រុង "ដើម្បីជ្រាប"
- បិទផ្សាយនៅក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន នាយកដ្ឋានអធិការកិច្ចការងារ និងអធិការដ្ឋាន សង្គមកិច្ច ការងារ និងអតីតយុទ្ធជន ខេត្ត-ក្រុង
- កាលប្បវត្តិ និងឯកសារ

**ស៊ុយ សែម**